DATE: January 26, 2022

Medi-Cal Eligibility Division Information Letter No.: I 22-02

TO: ALL COUNTY WELFARE DIRECTORS
ALL COUNTY ADMINISTRATIVE OFFICERS
ALL COUNTY MEDI-CAL PROGRAM SPECIALISTS/LIAISONS

SUBJECT: OLDER ADULT EXPANSION AND ASSET LIMIT CHANGES GLOBAL OUTREACH LANGUAGE

The purpose of this Medi-Cal Eligibility Division Information Letter (MEDIL) is to provide counties with global outreach language related to the Older Adult Expansion and changes to the asset limits for Non-MAGI Medi-Cal, for immediate use. The goal of the outreach language is to inform beneficiaries and prospective applicants of upcoming changes to Medi-Cal which will expand eligibility for full scope Medi-Cal to all individuals who are 50 years of age or older who meet all Medi-Cal eligibility criteria and immigration status does not matter. Additionally, the outreach language provides information to counties, beneficiaries, and applicants on increased limits on net, non-exempt assets in order to inform choices about applying for Medi-Cal.

**Background**

The global outreach language includes messaging that can be used in various forms of outreach including social media posts, call scripts, and county website content. While counties are not required to utilize this language, the Department of Health Care Services (DHCS) highly recommends counties utilize this messaging and integrate it into their outreach and social media campaigns. Counties may modify the global outreach language to meet any business need in utilizing the language; however, the intent of the language must remain the same to retain consistency in messaging.

DHCS is sharing the global outreach language broadly for use by Medi-Cal Managed Care Plans, other State departments, Medi-Cal providers, and other community partners for use in their outreach activities.

If you have any questions or require additional information, please contact:

- Jillian Davis by phone at (916) 345-8172 or by email at Jillian.Davis@dhcs.ca.gov
- Daniela Gutierrez by phone at (916) 345-8501 or by email at Daniela.Gutierrez@dhcs.ca.gov.

**ORIGINAL SIGNED BY**

Sandra Williams, Chief
Medi-Cal Eligibility Division

Enclosures

**DEPARTMENT OF HEALTH CARE SERVICES**

## Global Language and Messaging Snippets

**Flyer/Insert Snippet**

ជូនចំពោះសមាជិក ឬអ្នកដាក់ពាក្យសុំ Medi-Cal

នឹងមានការផ្លាស់ប្តូរនានាទៅលើកម្មវិធី Medi-Cal សម្រាប់មនុស្សចាស់និងជនពិការ ដែលនឹងធ្វើឲ្យមនុស្សកាន់តែច្រើនអាចទទួលបានការធានារ៉ាប់រង Medi-Cal។ ការផ្លាស់ប្តូរទាំងនេះ ក៏នឹងអនុញ្ញាតឲ្យមនុស្សរក្សាទុកទ្រព្យសម្បត្តិច្រើនជាងមុន នៅពេលពួកគេមាន Medi-Cal។

**Older Adult Expansion**

Older Adult Expansion នឹងមានប្រសិទ្ធភាពនៅថ្ងៃទី1 ខែឧសភា ឆ្នាំ2022។ ការពង្រីកវិសាលភាពនេះគឺពន្យារសិទ្ធិទទួលបាន full scope Medi-Cal ដល់មនុស្សដែលមានអាយុ 50 ឆ្នាំឬចាស់ជាងនេះ ដែលបំពេញរាល់លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal ទាំងអស់ ហើយស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ ប្រសិនបើអ្នកមាន restricted scope Medi-Cal ដែលកំពុងដំណើរការនៅក្នុងខែឧសភា ឆ្នាំ2022 នោះអ្នកនឹងត្រូវបានផ្ទេរដោយស្វ័យប្រវត្តិទៅកាន់ full scope Medi-Cal។ ប្រសិនបើអ្នកទទួលបានការជូនដំណឹងអំពីការបន្តសុពលភាព សូមបំពេញ រួចប្រគល់វាទៅឲ្យខោនធី ដើម្បីកុំឲ្យមានការពន្យារពេលកិច្ចដំណើរការ។

ប្រសិនបើអ្នកមិនមាន restricted scope Medi-Cal ដែលកំពុងដំណើរការទេ អ្នកអាចដាក់ពាក្យសុំ Medi-Cal តាមអនឡាញ តាមសំបុត្រប្រៃសណីយ៍ តាមទូរសព្ទ នៅការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក តាមទូរសារ ឬដោយផ្ទាល់។ ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន full scope Medi-Cal ក្រោម Older Adult Expansion អ្នកនឹងទទួលបានការជូនដំណឹងមួយដើម្បីប្រាប់អ្នកអំពីសិទ្ធិទទួលបាន full scope Medi-Cal របស់អ្នក និងកាលបរិច្ឆេទចាប់ផ្តើមដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី1 ខែឧសភា ឆ្នាំ2022 ឬក្រោយពេលនោះ។

**ការផ្លាស់ប្តូរដែនកំណត់ទ្រព្យសម្បត្តិ**

នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2022 ដែនកំណត់ទ្រព្យសម្បត្តិសម្រាប់កម្មវិធី Medi-Cal សម្រាប់មនុស្សដែលមានអាយុ 65 ឆ្នាំឬចាស់ជាងនេះ ឬជនពិការ នឹងមានការកើតឡើង។ ការផ្លាស់ប្តូរទាំងនេះ អនុវត្តចំពោះវត្ថុនានាដែលអ្នកកាន់កាប់ ដែលរាប់ថាមានតម្លៃសម្រាប់សិទ្ធិទទួលបាន Medi-Cal។ សម្ភារៈទាំងនេះរួមមានគណនីធនាគារ សាច់ប្រាក់ យានយន្តនិងលំនៅដ្ឋានទីពីរ និងធនធានហិរញ្ញវត្ថុផ្សេងទៀត។ ដែនកំណត់ពីមុនគឺ $2,000 សម្រាប់មនុស្សម្នាក់ និង $3,000 សម្រាប់គូស្វាមីភរិយា។ ដែនកំណត់ថ្មីគឺ $130,000 សម្រាប់មនុស្សម្នាក់ និង $65,000 បន្ថែមទៀតសម្រាប់សមាជិកគ្រួសារបន្ថែមម្នាក់ៗ។ ប្រសិនបើអ្នកជឿថាអ្នកអាចនឹងមានសិទ្ធិទទួលបាន Medi-Cal នៅពេលដែលដែនកំណត់ថ្មីចាប់ផ្តើម នោះអ្នកត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យសុំ។ ប្រសិនបើអ្នកស្ថិតនៅក្នុងកម្មវិធី Medi-Cal ដែលមានដែនកំណត់ទ្រព្យសម្បត្តិស្រាប់ហើយ នោះអ្នកនឹងអាចរក្សាទុកទ្រព្យសម្បត្តិបានច្រើនអ្វីដែលអ្នកអាចរក្សាទុកពីមុនមក។ សូមទាក់ទងទៅកាន់ការិយាល័យ Medi-Cal ខោនធីតាមមូលដ្ឋានរបស់អ្នក ប្រសិនបើអ្នកមានសំណួរណាមួយ។

**តើមានសំណួរដែរឬទេ?**

DHCS

**DEPARTMENT OF HEALTH CARE SERVICES**

ប្រសិនបើអ្នកមានសំណួរណាមួយ ឬប្រសិនបើពាក្យសុំ Medi-Cal របស់អ្នកត្រូវបានបដិសេធ សូមទាក់ទងទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។ ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក នៅទីនេះ៖ http://dhcs.ca.gov/COL។

DEPARTMENT OF HEALTH CARE SERVICES

| Website Text for County Office |
| --- |
| នឹងមានការផ្លាស់ប្តូរនានាទៅលើកម្មវិធី Medi-Cal សម្រាប់មនុស្សចាស់និងជនពិការ ដែលនឹងធ្វើឲ្យមនុស្សកាន់តែច្រើនអាចទទួលបានការធានារ៉ាប់រង Medi-Cal។ អ្នករស់នៅក្នុងរដ្ឋ California ដែលមានអាយុ 50 ឆ្នាំឬចាស់ជាងនេះ ដែលបំពេញរាល់លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal ទាំងអស់ នឹងអាចទទួលបាន full scope Medi-Cal ហើយស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ មនុស្សផ្សេងទៀតនឹងរក្សាទុកទ្រព្យសម្បត្តិបានច្រើនជាងមុន (ដូចជាលុយនៅក្នុងគណនីចរន្ត ឬគណនីសន្សំ) ខណៈដែលបន្តទទួលបាន Medi-Cal។ |

| Website Banner |
| --- |
| **ចំណុចសំខាន់៖** ការផ្លាស់ប្តូរវិធាន Medi-Cal នឹងកើតមាន! Medi-Cal នឹងមានសម្រាប់ផ្តល់ជូនមនុស្សទាំងអស់ដែលមានអាយុ 50 ឆ្នាំឬចាស់ជាងនេះ ដែលបំពេញរាល់លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal ទាំងអស់ ហើយស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ ការផ្លាស់ប្តូរទាំងនេះក៏នឹងអនុញ្ញាតឲ្យមនុស្សរក្សាទ្រព្យសម្បត្តិច្រើនជាងមុន និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Medi-Cal។ សូមសាកសួរការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។ |

DEPARTMENT OF HEALTH CARE SERVICES

<table>
<tr><th colspan="2">Social Media</th></tr>
<tr><td>សារ</td><td>រូបភាព</td></tr>
<tr><td>តើអ្នកមានអាយុ 50ឆ្នាំ ឬចាស់ជាងនេះដែរឬទេ? តើអ្នកមិនអាចទទួលបាន full scope Medi-Cal ដោយសារតែស្ថានភាពអន្តោប្រវេសន៍របស់អ្នកដែរឬទេ? ចាប់ពីថ្ងៃទី1 ខែឧសភា ឆ្នាំ2022 អ្នករស់នៅក្នុងរដ្ឋCalifornia គ្រប់រូបដែលមានអាយុ 50 ឆ្នាំឬចាស់ជាងនេះ និងដែលបំពេញរាល់លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal ទាំងអស់ នឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន full scope Medi-Cal។ ស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ ដើម្បីដឹងថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬអត់ ឬដើម្បីទទួលបានព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។ <u>ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក</u>។</td><td>
</td></tr>
</table>

DHCS

**DEPARTMENT OF HEALTH CARE SERVICES**

តើអ្នកមានអាយុ 50ឆ្នាំ ឬចាស់ជាងនេះដែរឬទេ? តើអ្នកមិនអាចទទួលបាន full scope Medi-Cal ដោយសារតែស្ថានភាពអន្តោប្រវេសន៍របស់អ្នកដែរឬទេ? ចាប់ពីថ្ងៃទី1 ខែឧសភា ឆ្នាំ2022 អ្នករស់នៅក្នុងរដ្ឋ California គ្រប់រូបដែលមានអាយុ 50ឆ្នាំឬចាស់ជាងនេះ និងដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal នឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន full scope Medi-Cal។ ស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ ដើម្បីដឹងថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬអត់ ឬដើម្បីទទួលបានព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។ ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។




តើអ្នកដឹងទេថា ប្រសិនបើអ្នកគឺជាអ្នករស់នៅរដ្ឋ California ដែលមានអាយុ 50ឆ្នាំឬចាស់ជាងនេះ អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន full scope  Medi-Cal ចាប់ពីថ្ងៃទី1 ខែឧសភា ឆ្នាំ2022 ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក? សូមទាក់ទងទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក ដើម្បីដាក់ពាក្យសុំ និងស្វែងយល់បន្ថែម។ ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។



DEPARTMENT OF HEALTH CARE SERVICES

ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2022 ការផ្លាស់ប្តូរនានាចំពោះដែនកំណត់ទ្រព្យសម្បត្តិ អាចនឹងមានន័យថាអ្នកនឹងអាចមានទ្រព្យសម្បត្តិបន្ថែមទៀតបាន និងបន្តស្ថិតនៅក្នុង Medi-Cal តទៅទៀត។ សូមទាក់ទងទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។ ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។




ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2022 ការផ្លាស់ប្តូរនានាចំពោះដែនកំណត់ទ្រព្យសម្បត្តិ អាចនឹងមានន័យថា អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន Medi-Cal។ សូមសាកសួរការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។ ស្វែងរកការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នក។



**DEPARTMENT OF HEALTH CARE SERVICES**

| Call Script Snippet | |
|---|---|
| **អ្នកហៅទូរសព្ទ** | **ភ្នាក់ងារ** |
| តើ "ដែនកំណត់ទ្រព្យសម្បត្តិកើតឡើង" មានន័យដូចម្តេច? | Medi-Cal រាប់បញ្ចូលប្រភេទទ្រព្យសម្បត្តិជាក់លាក់ នៅពេលពិនិត្យមើលថាតើអ្នកអាចទទួលបានអត្ថប្រយោជន៍ Medi-Cal ដែរឬអត់។ ដែនកំណត់របស់ទ្រព្យដែលអ្នកអាចមាន (ដូចជាសាច់ប្រាក់ គណនីធនាគារ និងប្រភេទទ្រព្យសម្បត្តិផ្សេងទៀត) គឺ $2,000 សម្រាប់បុគ្គលម្នាក់ ប៉ុន្តែនឹងកើនឡើងរហូតដល់ $130,000 នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2022។ សូមសាកសួរការិយាល័យ Medi-Cal តាមមូលដ្ឋានរបស់អ្នក ថាតើការផ្លាស់ប្តូរទាំងនេះអនុវត្តចំពោះអ្នកដែរឬអត់។ [insert local county contact information] |
| តើ Older Adult Expansion ជាអ្វី? | នៅក្នុងខែឧសភា ឆ្នាំ2022 Older Adult Expansion នឹងពង្រីកវិសាលភាព full scope Medi-Cal ទៅដល់រាល់អ្នករស់នៅក្នុងរដ្ឋ California ដែលមានអាយុ 50 ឆ្នាំឬចាស់ជាងនេះ ប្រសិនបើបុគ្គលនោះបំពេញរាល់លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន Medi-Cal ទាំងអស់ ហើយស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ |
| តើខ្ញុំទទួលបានព័ត៌មានបន្ថែមអំពី Older Adult Expansion យ៉ាងដូចម្តេច? | ព័ត៌មានអំពី Older Adult Expansion អាចរកបាននៅលើគេហទំព័រ DHCS https://bit.ly/older-adult-expansion នៅក្នុង ACWDL 21-13, ឬតាមរយៈការផ្ញើអ៊ីម៉ែលទៅកាន់ OlderAdultExpansion@dhcs.ca.gov. |
| តើអត្ថប្រយោជន៍អ្វីខ្លះដែលត្រូវបានផ្តល់ជូនដោយ Older Adult Expansion? | អ្នកដែលមានសិទ្ធិទទួលបាន full scope Medi-Cal ដោយសារតែ Older Adult Expansion នឹងទទួលបានរាល់អត្ថប្រយោជន៍ full scope ទាំងអស់ដែលបានផ្តល់ជូន។<br><br>Full scope Medi-Cal ខុសពី restricted scope Medi-Cal។ Restricted scope Medi-Cal រ៉ាប់រងតែទៅលើសេវាកម្មមួយចំនួនតូចប៉ុណ្ណោះ។ Restricted scope Medi-Cal មិនរ៉ាប់រងលើសេវាដូចជាថ្នាំពេទ្យ ឬការថែទាំបឋមនោះទេ។<br><br>Full scope Medi-Cal ផ្តល់ការថែទាំសុខភាពគ្រប់ជ្រុងជ្រោយ មានដូចជាផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ សុខភាពផ្លូវចិត្ត ការធ្វើផែនការគ្រួសារ ការថែទាំជើង សម្ភារៈជំនួយការ |

| | |
|---|---|
| | ស្តាប់ និងការថែទាំភ្នែក (វ៉ែនតា) រួមទាំងសេវានានាដើម្បីជួយអ្នកឲ្យបន្តស្ថិតនៅក្នុងផ្ទះ ដូចជា In-Home Supportive Services ប្រសិនបើអ្នកត្រូវការជំនួយលើសកម្មភាពប្រចាំថ្ងៃ។ Full scope Medi-Cal ក៏រ៉ាប់រងផងដែរលើការព្យាបាលសម្រាប់ការសេពគ្រឿងស្រវឹងនិងថ្នាំញៀន ថ្នាំពេទ្យដែលវេជ្ជបណ្ឌិតរបស់អ្នកចេញវេជ្ជបញ្ជាជូន និងសេវាជាច្រើនទៀត។ |

DEPARTMENT OF HEALTH CARE SERVICES

| IVR Call Script |
| --- |
| ដែនកំណត់ទ្រព្យសម្បត្តិសម្រាប់កម្មវិធី Medi-Cal របស់អ្នក នឹងកើនឡើងចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2022។ អ្នកអាចនឹងអាចមាន ឬសន្សំប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀតបានច្រើនជាងមុន បន្ទាប់ពីការកើនឡើងនោះចាប់ផ្តើម។ សូមទូរសព្ទទៅកាន់ការិយាល័យខោនធីតាមមូលដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។ |
| ចាប់ពីថ្ងៃទី1 ខែឧសភា ឆ្នាំ2022 អ្នកអាចនឹងមានសិទ្ធិទទួលបាន full scope Medi-Cal ដោយសារតែ Older Adult Expansion។ Older Adult Expansion នឹងពង្រីកវិសាលភាពសិទ្ធិទទួលបាន full scope Medi-Cal ទៅដល់អ្នករស់នៅរដ្ឋ California ទាំងអស់ដែលមានអាយុ 50ឆ្នាំឬចាស់ជាងនេះ ប្រសិនបើបុគ្គលនោះបំពេញរាល់លក្ខខណ្ឌតម្រូវសិទ្ធិទទួលបាន Medi-Cal ទាំងអស់ ហើយស្ថានភាពអន្តោប្រវេសន៍មិនសំខាន់នោះទេ។ |
| អ្នកដាក់ពាក្យសុំថ្មីត្រូវតែដាក់ពាក្យសុំ Medi-Cal ដើម្បីដឹងថាតើពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន full scope Medi-Cal ដោយសារ Older Adult Expansion ដែរឬអត់។ អ្នកទទួលផល Medi-Cal ពីមុនមក នឹងត្រូវបានផ្ទេរដោយស្វ័យប្រវត្តិទៅកាន់សិទ្ធិទទួលបាន full scope និងទទួលបានអត្ថប្រយោជន៍ថែទាំសុខភាពបន្ថែមទៀត នៅពេល Older Adult Expansion ត្រូវបានអនុវត្តនៅថ្ងៃទី1 ខែឧសភា ឆ្នាំ2022។ |